ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករធានារ៉ាប់រងកម្ពុជា
លេខ...០៤៧......ន.ធ.ក./សណន

# សេចក្តីណែនាំ
# ស្តីពី
# គោលការណ៍អប្បបរមាចំពោះកិច្ចសន្យាធានារ៉ាប់រងខ្នាតតូច

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង, ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ប្រកាសលេខ ០៣៣ អ.ស.ហ.ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកំណត់ទូទៅចំពោះគ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង, ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធការធានារ៉ាប់រង និយ័តករធានារ៉ាប់រងកម្ពុជាសូមចេញសេចក្តីណែនាំស្តីពី **"គោលការណ៍អប្បបរមាចំពោះកិច្ចសន្យាធានារ៉ាប់រងខ្នាតតូច"** ក្នុងគោលបំណងផ្តល់ការការពារអត្ថប្រយោជន៍របស់អ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ដោយកំណត់គោលការណ៍អប្បបរមាចំពោះកិច្ចសន្យាធានារ៉ាប់រងខ្នាតតូចដូចខាងក្រោម៖

## ១.កិច្ចសន្យាធានារ៉ាប់រងខ្នាតតូច

កិច្ចសន្យាធានារ៉ាប់រងខ្នាតតូច ជាកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និងអ្នកត្រូវបានធានារ៉ាប់រង ដែលតាមរយៈនោះ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចព្រមទទួលនូវហានិភ័យជាក់លាក់ណាមួយ ដោយទទួលមកវិញនូវការបង់បុព្វលាភធានារ៉ាប់រងពីអ្នកដែលត្រូវបានធានារ៉ាប់រង។

កិច្ចសន្យាធានារ៉ាប់រងខ្នាតតូចមួយ ត្រូវមានចំនួនទឹកប្រាក់អតិបរមាដែលត្រូវបានធានារ៉ាប់រងមិនលើសពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល។

អនុលោមតាមមាត្រា៨ នៃច្បាប់ស្តីពីការធានារ៉ាប់រង កិច្ចសន្យាធានារ៉ាប់រងត្រូវតែចែងឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងរវាងសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រង។ កិច្ចសន្យាធានារ៉ាប់រង ត្រូវរៀបចំដោយយកភាសាខ្មែរជាគោលនិងត្រូវមានចុះហត្ថលេខា និង/ឬ

ផ្ដិតមេដៃរបស់ភាគីទាំងសងខាង។ ដោយឡែកការបង្កើតកិច្ចសន្យារ៉ាប់រងខ្នាតតូចតាមប្រព័ន្ធទូរស័ព្ទ ត្រូវអនុវត្តតាមចំណុចទី ១.២ នៃសេចក្ដីណែនាំនេះ។

បន្ទាប់ពីបានចុះកិច្ចសន្យារ៉ាប់រងខ្នាតតូចរួចមក ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចត្រូវចេញបណ្ណសន្យារ៉ាប់រងខ្នាតតូច និងវិញ្ញាបនបត្រធានារ៉ាប់រងខ្នាតតូច និង/ឬឯកសារពាក់ព័ន្ធផ្សេងៗទៀតឱ្យទៅម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង។

### ១.១.ទម្រង់នៃវិញ្ញាបនបត្រធានារ៉ាប់រង និងបណ្ណសន្យារ៉ាប់រងខ្នាតតូច

ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ត្រូវចេញវិញ្ញាបនបត្រធានារ៉ាប់រងដោយភ្ជាប់ជាមួយបណ្ណសន្យារ៉ាប់រងខ្នាតតូចក្នុងទម្រង់ជាឯកសារតែមួយ និងត្រូវប្រើប្រាស់ភាសាខ្មែរជាគោល ដោយមានពុម្ពអក្សរខ្មែរយូនីកូដ ទំហំ ១១។ ឯកសារនេះ ត្រូវបោះត្រា និង/ឬហត្ថលេខារបស់ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច។ វិញ្ញាបនបត្រធានារ៉ាប់រង និងបណ្ណសន្យារ៉ាប់រងខ្នាតតូចត្រូវកំណត់ដូចខាងក្រោម៖

#### ១.១.១.វិញ្ញាបនបត្រធានារ៉ាប់រងខ្នាតតូច

លើកលែងតែវិញ្ញាបនបត្រធានារ៉ាប់រងខ្នាតតូចដែលផ្ដល់តាមប្រព័ន្ធទូរស័ព្ទ វិញ្ញាបនបត្រធានារ៉ាប់រងខ្នាតតូច ត្រូវបញ្ជាក់និទ្ទេសអប្បបរមាដូចខាងក្រោម៖

- លេខវិញ្ញាបនបត្រធានារ៉ាប់រងខ្នាតតូច
- គោត្តនាម និងនាម និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា
- បុគ្គល ឬវត្ថុដែលត្រូវបានធានារ៉ាប់រង
- ប្រភេទហានិភ័យដែលត្រូវបានធានារ៉ាប់រង
- ពេលវេលាចាប់ផ្ដើម និងទីកន្លែងនៃហានិភ័យដែលត្រូវបានធានារ៉ាប់រង
- ចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង
- បុព្វលាភធានារ៉ាប់រងដែលត្រូវបង់ និងរបៀបបង់បុព្វលាភធានារ៉ាប់រង
- របៀបនិងលក្ខខណ្ឌមួយចំនួននៃសេចក្ដីប្រកាសគ្រោះថ្នាក់
- រយៈពេលនៃកិច្ចសន្យា និងរយៈពេលនៃការធានារ៉ាប់រង
- លក្ខខណ្ឌទាំងឡាយណាដែលកំណត់មោឃភាព និងការបាត់បង់សិទ្ធិព្រមទាំងលក្ខខណ្ឌដែលអនុញ្ញាតឱ្យគូភាគីនីមួយៗបញ្ចប់កិច្ចសន្យាបានមុនកាលកំណត់។

ក្រៅពីចំណុចដែលមានកំណត់ខាងលើ គូភាគីអាចដាក់បន្ថែមនូវចំណុចផ្សេងៗទៀតបាន ដោយមានការព្រមព្រៀងគ្នាជាមុន។

#### ១.១.២.បណ្ណសន្យារ៉ាប់រងខ្នាតតូច

បណ្ណសន្យារ៉ាប់រងខ្នាតតូច ត្រូវមានភាពសាមញ្ញ និងងាយយល់ និងត្រូវរៀបចំឡើងក្នុងទម្រង់ដែលមានបង្ហាញអត្តសញ្ញាណច្បាស់លាស់រួមមាន និមិត្តសញ្ញា និងត្រារបស់ក្រុមហ៊ុន។ បណ្ណសន្យារ៉ាប់រងខ្នាតតូច ត្រូវមានមាតិកាអប្បបរមា និងតាមលំដាប់ដូចខាងក្រោម៖

ក- អត្ថប្រយោជន៍នៃការធានា៖ កំណត់អត្ថប្រយោជន៍ ឬសំណងដែលម្ចាស់បណ្ណសន្យារ៉ាប់រងខ្នាតតូច ឬអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬតតិយជន នឹងទទួលបានពេលមានហានិភ័យកើតឡើងបណ្ដាលឱ្យកម្មវត្ថុនៃការធានាទទួលរងការខូចខាត ឬបាត់បង់។

ខ- ករណីមិនធានា៖ កំណត់ហានិភ័យដែលក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច មិនធ្វើសំណងធានារ៉ាប់រងដល់ម្ចាស់បណ្ណសន្យារ៉ាប់រងខ្នាតតូច ឬអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬតតិយជន នៅពេលមានហានិភ័យកើតឡើងបណ្ដាលឱ្យកម្មវត្ថុនៃការធានាទទួលរងការខូចខាត ឬបាត់បង់។

គ- ការបញ្ចប់ និងការលុបចោលកិច្ចសន្យាធានារ៉ាប់រង៖ កំណត់លក្ខខណ្ឌ និងនីតិវិធីនៃការបញ្ចប់ និងការលុបចោលកិច្ចសន្យាធានារ៉ាបរងខ្នាតតូចដោយម្ចាស់បណ្ណសន្យារ៉ាប់រងខ្នាតតូច ឬក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និងក្នុងករណីមានការបញ្ចប់កិច្ចសន្យាធានារ៉ាប់រងខ្នាតតូចមុនកាលកំណត់ បណ្ណសន្យារ៉ាប់រងខ្នាតតូចត្រូវចែងពីកាតព្វកិច្ចរបស់ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចក្នុងការបង្វិលសងវិញនូវបុព្វលាភធានារ៉ាប់រងសម្រាប់រយៈពេលដែលនៅសល់។

ឃ- ការទាមទារសំណងធានារ៉ាប់រង៖ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ត្រូវកំណត់អំពីបែបបទ និងនីតិវិធីនៃការទាមទារសំណងធានារ៉ាប់រង ស្របតាមគោលការណ៍ណែនាំស្ដីពីការទទួល និងដោះស្រាយសំណងធានារ៉ាប់រង

ង- ការផ្សះផ្សាវិវាទ៖ ត្រូវចែងថា "ចំពោះគ្រប់វិវាទនៃកិច្ចសន្យាធានារ៉ាប់រងនេះដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូននិយ័តករធានារ៉ាប់រងកម្ពុជាដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុននឹងប្ដឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ច លើកលែងតែរឿងព្រហ្មទណ្ឌ"។

ក្រៅពីចំណុចដែលមានកំណត់ខាងលើ គូភាគីអាចដាក់បន្ថែមនូវចំណុចផ្សេងៗទៀតបានដោយមានការព្រមព្រៀងគ្នាជាមុន។

## ១.២.ការបង្កើតកិច្ចសន្យាធានារ៉ាប់រងខ្នាតតូចតាមប្រព័ន្ធទូរស័ព្ទ

អនុលោមតាមមាត្រា១២ នៃច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កិច្ចសន្យាធានារ៉ាប់រងខ្នាតតូច ដែលធ្វើឡើងតាមមធ្យោបាយអេឡិចត្រូនិក មានសុពលភាព អានុភាពគតិយុត្ត និងភាពអាចអនុវត្តបាន នៅពេលដែលសំណើនិងស្វីការត្រូវគ្នា។ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ដែលផ្ដល់ការធានារ៉ាប់រងខ្នាតតូចតាមប្រព័ន្ធទូរស័ព្ទត្រូវបង្ហាញឱ្យច្បាស់នូវសំណើ និងស្វីការរវាងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និងម្ចាស់បណ្ណសន្យារ៉ាប់រងខ្នាតតូច ឬអ្នកត្រូវបានធានារ៉ាប់រង។

### ១.២.១.ទម្រង់នៃបណ្ណសន្យារ៉ាប់រងខ្នាតតូច និងវិញ្ញាបនបត្រធានារ៉ាប់រងខ្នាតតូចតាមប្រព័ន្ធទូរស័ព្ទ

ទោះបីជាមានមាត្រា៩ និងមាត្រា១៤ នៃច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏ដោយ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចដែលផ្ដល់ការធានារ៉ាប់រងតាមប្រព័ន្ធទូរស័ព្ទ ត្រូវផ្ដល់វិញ្ញាបនបត្រធានារ៉ាប់រង និងបណ្ណសន្យាធានារ៉ាប់រងខ្នាតតូច ដែលមានព័ត៌មានអប្បបរមាដូចខាងក្រោម៖

### ១.២.១.១.វិញ្ញាបនបត្រធានារ៉ាប់រងខ្នាតតូចតាមប្រព័ន្ធទូរស័ព្ទ

ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចដែលផ្តល់ការធានារ៉ាប់រងតាមប្រព័ន្ធទូរស័ព្ទ ត្រូវផ្តល់វិញ្ញាបនបត្រធានារ៉ាប់រងខ្នាតតូច ដែលមានព័ត៌មានអប្បបរមាដូចខាងក្រោម៖

- លេខវិញ្ញាបនបត្រធានារ៉ាប់រងខ្នាតតូច
- ព័ត៌មានរបស់ម្ចាស់បណ្ណសន្យារ៉ាប់រងនិង/ឬអ្នកត្រូវបានធានារ៉ាប់រង និងអ្នកទទួលផល ឬវត្ថុដែលត្រូវបានធានារ៉ាប់រង (ប្រសិនបើមាន)
- កាលបរិច្ឆេទចាប់ផ្តើមនិងបញ្ចប់នៃការធានារ៉ាប់រង និងរយៈពេលនៃការធានារ៉ាប់រង
- ទីកន្លែងនៃហានិភ័យដែលត្រូវបានធានារ៉ាប់រង
- ចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង
- បុព្វលាភធានារ៉ាប់រងដែលត្រូវបង់ និងរបៀបបង់បុព្វលាភធានារ៉ាប់រង។

### ១.២.១.២.បណ្ណសន្យារ៉ាប់រងខ្នាតតូចតាមប្រព័ន្ធទូរស័ព្ទ

ចំណុច ១.១.២. (បណ្ណសន្យារ៉ាប់រងខ្នាតតូច) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការផ្តល់បណ្ណសន្យារ៉ាប់រងខ្នាតតូចតាមប្រព័ន្ធទូរស័ព្ទ។

## ២.ការផ្តល់ព័ត៌មានអំពីការធានារ៉ាប់រងខ្នាតតូចសម្រាប់ការលក់តាមប្រព័ន្ធទូរស័ព្ទ

ក្នុងករណីដែលម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងយល់ព្រមទទួលយកការធានារ៉ាប់រងខ្នាតតូចតាមរយៈប្រព័ន្ធទូរស័ព្ទ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ត្រូវផ្តល់ព័ត៌មានសង្ខេបអំពីការធានារ៉ាប់រងខ្នាតតូចជាភាសាខ្មែរ តាមរយៈសារអេឡិចត្រូនិក (SMS) ជូនម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង។ ព័ត៌មានសង្ខេបអំពីការធានារ៉ាប់រងត្រូវមានភាពងាយស្រួលយល់ និងត្រូវមានព័ត៌មានជាអាទិ៍ ដូចខាងក្រោម៖

- ឈ្មោះផលិតផលធានារ៉ាប់រង
- គោត្តនាម និងនាមរបស់ម្ចាស់បណ្ណសន្យារ៉ាប់រងនិង/ឬអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផលដែលត្រូវបានធានារ៉ាប់រង
- កាលបរិច្ឆេទចាប់ផ្តើមនិងបញ្ចប់នៃការធានារ៉ាប់រង
- អត្ថប្រយោជន៍នៃការធានារ៉ាប់រងជាក់លាក់
- ទឹកប្រាក់ត្រូវបានធានារ៉ាប់រង និងបុព្វលាភធានារ៉ាប់រង
- លេខទំនាក់ទំនងរបស់ក្រុមហ៊ុនធានារ៉ាប់រង
- តំណភ្ជាប់ (Link) សម្រាប់ចូលយកវិញ្ញាបនបត្រធានារ៉ាប់រង និងបណ្ណសន្យារ៉ាប់រងខ្នាតតូចពេញលេញ និងអាចទាញយកទៅប្រើប្រាស់នៅពេលក្រោយបាន។ វិញ្ញាបនបត្រធានារ៉ាប់រង និងបណ្ណសន្យារ៉ាប់រងខ្នាតតូច ដែលផ្តល់តាមតំណភ្ជាប់ (Link) នេះ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ត្រូវប្រើប្រាស់គម្រូនៃកិច្ចសន្យាធានារ៉ាប់រងខ្នាតតូច ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

## ៣.ការបន្តកិច្ចសន្យាធានារ៉ាប់រងខ្នាតតូច

កិច្ចសន្យាធានារ៉ាប់រងខ្នាតតូចត្រូវបន្តសុពលភាពនៃការធានារ៉ាប់រង ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចមិនបដិសេធនូវសំណើសុំបន្តកិច្ចសន្យារ៉ាប់រងខ្នាតតូចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានការស្នើសុំ។ ក្នុងករណីកិច្ចសន្យាធានារ៉ាប់រងខ្នាតតូចត្រូវបានបន្ត ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ត្រូវផ្តល់វិញ្ញាបនបត្រធានារ៉ាប់រង និងបណ្ណសន្យារ៉ាប់រងខ្នាតតូច ដូចមានកំណត់ក្នុងចំណុច ១.១ (ទម្រង់នៃវិញ្ញាបនបត្រធានារ៉ាប់រង និងបណ្ណសន្យារ៉ាប់រងខ្នាតតូច) ខាងលើ។ ដោយឡែក ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចដែលអនុវត្តតាមទម្រង់វិញ្ញាបនបត្រធានារ៉ាប់រង និងបណ្ណសន្យារ៉ាប់រងខ្នាតតូច ដែលទទួលបានការអនុញ្ញាតមុនពេលសេចក្តីណែនាំនេះចូលជាធរមាន ត្រូវផ្តល់វិញ្ញាបនបត្រធានារ៉ាប់រងខ្នាតតូចជូនម្ចាស់បណ្ណសន្យារ៉ាប់រង។

ក្នុងករណីការបន្តកិច្ចសន្យាធានារ៉ាប់រងខ្នាតតូចតាមប្រព័ន្ធទូរស័ព្ទ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ត្រូវផ្តល់ព័ត៌មានសង្ខេបអំពីការធានារ៉ាប់រងខ្នាតតូចជាភាសាខ្មែរ តាមរយៈសារអេឡិចត្រូនិក (SMS) ជូនម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង ដូចបានកំណត់ក្នុងចំណុចទី២ (ការផ្តល់ព័ត៌មានអំពីការធានារ៉ាប់រងខ្នាតតូចសម្រាប់ការលក់តាមប្រព័ន្ធទូរស័ព្ទ) នៃសេចក្តីណែនាំនេះ។

## ៤.ការបង់បុព្វលាភធានារ៉ាប់រង

ការបង់បុព្វលាភធានារ៉ាប់រងខ្នាតតូច អាចធ្វើឡើងតាមរយៈមធ្យោបាយដែលមានជាអាទិ៍ ដូចខាងក្រោម៖

ក- ការកាត់សមតុល្យសាច់ប្រាក់ក្នុងទូរស័ព្ទចល័តរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង។

ខ- ឧបករណ៍ទូទាត់អេឡិចត្រូនិក។

គ- ការបង់ជាសាច់ប្រាក់។

## ៥.ការទូទាត់សំណងធានារ៉ាប់រង

ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ត្រូវទូទាត់សំណងធានារ៉ាប់រងតាមមធ្យោបាយដែលមានជាអាទិ៍ ដូចខាងក្រោម៖

ក- ការបង់ជាសាច់ប្រាក់។

ខ- ឧបករណ៍ទូទាត់អេឡិចត្រូនិក។

ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច មិនត្រូវទូទាត់សំណងធានារ៉ាប់រងជាសមតុល្យសាច់ប្រាក់ក្នុងប្រព័ន្ធទូរស័ព្ទចល័តរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងនោះឡើយ។ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ប៉ុន្តែមិនត្រូវមានចំនួនលើសពី ៥ (ប្រាំ) ដុល្លារអាម៉េរិកឡើយ។

## ៦.ការអនុវត្ត

វិញ្ញាបនបត្រធានារ៉ាប់រងខ្នាតតូច និងបណ្ណសន្យារ៉ាប់រងខ្នាតតូច ដែលបានទទួលការអនុញ្ញាត

ពី **ន.ធ.ក**. រួចហើយ ត្រូវបន្តអនុវត្ត លើកលែងតែក្នុងករណីក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចស្នើសុំកែប្រែតាមខ្លឹមសារនៃសេចក្តីណែនាំនេះ។

ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចណាដែលមិនគោរពតាមសេចក្តីណែនាំនេះត្រូវទទួលទោស ដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ៧.សុពលភាពនៃសេចក្តីណែនាំ

ទទួលបានសេចក្តីណែនាំនេះ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចទាំងអស់ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែកញ្ញា គ.ស.២០២៤

**អគ្គនាយក**
**និយ័តករធានារ៉ាប់រងកម្ពុជា**

ប៊ូ ច័ន្ទភិរុ

**ចម្លងជូន៖**

-អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
-ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធនៃសេចក្តីណែនាំលេខ ០៤២ ន.ធ.ក./សណាន
# ស្តីពីគោលការណ៍អប្បបរមាចំពោះកិច្ចសន្យាធានារ៉ាប់រងខ្នាតតូច
# ចុះថ្ងៃទី ៥ ខែ កញ្ញា គ.ស.២០២៤

## គម្រូកិច្ចសន្យាធានារ៉ាប់រងខ្នាតតូច

<ឈ្មោះក្រុមហ៊ុនធានារ៉ាប់រង>

<អាស័យដ្ឋានក្រុមហ៊ុនធានារ៉ាប់រង>

<លេខទូរស័ព្ទក្រុមហ៊ុនធានារ៉ាប់រង>

## វិញ្ញាបនបត្រធានារ៉ាប់រងខ្នាតតូច

| | |
|---|---|
| លេខកិច្ចសន្យាធានារ៉ាប់រងខ្នាតតូច | : ០០០០០០០០១ |
| ព័ត៌មានរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង | : ឈ្មោះ, ថ្ងៃខែឆ្នាំកំណើត, លេខអត្តសញ្ញាណប័ណ្ណ និងអាសយដ្ឋាន |
| ព័ត៌មានរបស់អ្នកត្រូវបានធានារ៉ាប់រង | : ឈ្មោះ, ថ្ងៃខែឆ្នាំកំណើត និងលេខអត្តសញ្ញាណប័ណ្ណ |
| ព័ត៌មានរបស់អ្នកទទួលផល | : ឈ្មោះ, ថ្ងៃខែឆ្នាំកំណើត និងលេខអត្តសញ្ញាណប័ណ្ណ (ករណីធានារ៉ាប់រងអាយុជីវិត) |
| ព័ត៌មានរបស់វត្ថុដែលត្រូវបានធានា | : ..................... (ករណីធានារ៉ាប់រងទូទៅ) |
| ប្រភេទហានិភ័យដែលត្រូវបានធានា | : ..................... |
| រយៈពេលនៃកិច្ចសន្យា និងការធានារ៉ាប់រង | : ..................... |
| កាលបរិច្ឆេទចាប់ផ្តើមការធានារ៉ាប់រង | : ថ្ងៃ.....ខែ...... ឆ្នាំ...... |
| កាលបរិច្ឆេទបញ្ចប់ការធានារ៉ាប់រង | : ថ្ងៃ.....ខែ...... ឆ្នាំ...... (បន្ថែម) |
| ទីកន្លែងនៃហានិភ័យដែលត្រូវបានធានា | : ..................... |
| របៀបបង់បុព្វលាភធានារ៉ាប់រង | : ..................... |

| ឈ្មោះផលិតផលធានារ៉ាប់រង | ចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង | ចំនួនបុព្វលាភធានារ៉ាប់រង | តម្លៃនៃការបោះបង់កិច្ចសន្យាធានារ៉ាប់រង (ប្រសិនបើមាន) |
|---|---|---|---|
| | | | |

របៀបនិងលក្ខខណ្ឌមួយចំនួននៃសេចក្តីប្រកាសគ្រោះថ្នាក់: .....................

លក្ខខណ្ឌទាំងឡាយណាដែលកំណត់មោឃភាព និងការបាត់បង់សិទ្ធិព្រមទាំងលក្ខខណ្ឌដែលអនុញ្ញាតឱ្យភាគីនីមួយៗបញ្ឈប់កិច្ចសន្យាបានមុនកាលកំណត់: .....................

## បណ្ណសន្យារ៉ាប់រងខ្នាតតូច

### ក.អត្ថប្រយោជន៍នៃការធានា

កំណត់អត្ថប្រយោជន៍ ឬសំណងដែលម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬតតិយជន នឹងទទួលបានពេលមានហានិភ័យកើតឡើងបណ្តាលឱ្យកម្មវត្ថុនៃការធានាទទួលរងការខូចខាត ឬបាត់បង់។

### ខ.ករណីមិនធានា

កំណត់ហានិភ័យដែលក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច មិនធ្វើសំណងដល់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬតតិយជន នៅពេលមានហានិភ័យកើតឡើងបណ្តាលឱ្យកម្មវត្ថុនៃការធានាទទួលរងការខូចខាត ឬបាត់បង់។

### គ.ការបញ្ចប់ និងការលុបចោលកិច្ចសន្យាធានារ៉ាប់រង

កំណត់លក្ខខណ្ឌ និងនីតិវិធីនៃការបញ្ចប់ និងការលុបចោលកិច្ចសន្យាធានារ៉ាបរងខ្នាតតូចដោយម្ចាស់បណ្ណ-សន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង ឬក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច។

### ឃ.ការទាមទារសំណងធានារ៉ាប់រង

កំណត់លក្ខខណ្ឌ និងនីតិវិធីទាមទារសំណងធានារ៉ាប់រង ស្របតាមគោលការណ៍ណែនាំស្តីពីការទទួល និងដោះស្រាយសំណងធានារ៉ាប់រង។

### ង.ការផ្សះផ្សាវិវាទ

ត្រូវចែងថា "ចំពោះគ្រប់វិវាទនៃកិច្ចសន្យាធានារ៉ាប់រងនេះដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូននិយ័តករធានារ៉ាប់រងកម្ពុជាដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ច លើកលែងតែរឿងព្រហ្មទណ្ឌ"។

ត្រា និង/ឬហត្ថលេខារបស់ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច